ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៨៨

ចុះថ្ងៃទី០៣ខែសីហាឆ្នាំ២០០០

សាលដីកា

លេខ : ១២៩

ចុះថ្ងៃទី២៨ខែសីហាឆ្នាំ២០០១

ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០១ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ប្រាក់ គឹមសាន ជាចៅក្រម

៣- លោក ស៊ុន ឌឹម ជាចៅក្រម

៤- លោក ឈឹម ស៊ីផល ជាចៅក្រម

៥- លោក សោម សិរីវឌ្ឍ ជាចៅក្រមរាយការណ៍

ក្រឡាបញ្ជី

កញ្ញា សេន សុខា

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ១១៧ "ង" ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ១០២ ចុះថ្ងៃទី ១៤ ខែកម្ភៈ ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍រវាង :

ម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ហាក់ សារិទ្ធិ អាយុ ៥៤ឆ្នាំ ជាតិ ខ្មែរ មុខរបរ គ្រូបង្រៀន ទីលំនៅ ផ្ទះលេខ ៨៤៥ ផ្លូវ ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ មានមេធាវីលោក ចាន់ សុខយាង

និងចុងបណ្តឹងសាទុក្ខឈ្មោះ ចៅ ហុង អាយុ៤៩ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅ ផ្ទះលេខ៨៤៥ ផ្លូវលេខ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ មានមេធាវី លោក សែម ចិន្តា

តតិយជនឈ្មោះ សុខ យឹង អាយុ ៥៤ឆ្នាំ ជាតិ ខ្មែរ មុខរបរ លក់ដូរ ទីលំនៅ ផ្ទះលេខ៨៤៥ ផ្លូវលេខ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

កម្មវត្ថុបណ្តឹង : ប្តឹងទាមទារទៅរស់

តាមបណ្តឹងសាទុក្ខលេខ ២៥៩ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០០ របស់ លោក ហាក់ សារិទ្ធិ បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីកាលេខ ១១៧ "ង" ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

--- ---

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៨៨ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៧.៥.៩៩ និង ២៤.៥.៩៩ របស់ដើមចោទឈ្មោះ ហាក់ សារិទ្ធិ ថា : ខ្លួនប្តឹងទាមទារទែរ៉ាស់ផ្ទះលេខ ៨៤៥ទាំងមូល ស្ថិតនៅផ្លូវ ២៧១ ក្រុម៤៤ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ មូលហេតុជាទែរ៉ាស់របស់ខ្លួនដែលថែរក្សាតាំងពីឆ្នាំ ១៩៨០ រហូតមក ។

តាមពាក្យបណ្តឹងតបចុះថ្ងៃទី ០៤.៨.៩៩ របស់ចុងចម្លើយ និងជាដើមបណ្តឹងតបឈ្មោះ ង៉ោ ហុង ថា ខ្លួនប្តឹងទាមទារទែរ៉ាស់របស់ខ្លួនតាមទំហំផ្ទះរបស់ខ្លួនដូចខាងក្រោមដែលហាក់សា-រិទ្ធិប្រុងដណ្តើមកាន់កាប់ ។ មូលហេតុជាទែរ៉ាស់ផ្ទះរបស់ខ្លួន ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១១.៨.៩៩ របស់តតិយជនឈ្មោះ សុខ ដឹងថា ខ្លួនប្តឹងទាមទារកាន់កាប់ទែរ៉ាស់ផ្ទះរបស់ខ្លួន និង ជំទាស់ពី ហាក់ សារិទ្ធិ ដែលទាមទារកាន់កាប់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៧៤ "១" ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ០៧.៥.១៩៩៩ និង ចុះថ្ងៃទី ២៤.៥.១៩៩៩ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយពីគតិច្បាប់ ។

២- ទទួលស្គាល់ពាក្យបណ្តឹងតបចុះថ្ងៃទី ០៤.៨.១៩៩៩ របស់ចុងចម្លើយ និង ដើមបណ្តឹងតបឈ្មោះ ង៉ោ ហុង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១១.៨.១៩៩៩ របស់តតិយជនឈ្មោះ សុខ ដឹង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៤- ទែរ៉ាស់ផ្ទះលេខ ៨៤៥អ៊ី០ ស្ថិតនៅផ្លូវលេខ ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ត្រូវបែងចែកជាបីចំណែក អោយទៅឈ្មោះ ង៉ោ ហុង ឈ្មោះ សុខ ដឹង និង ឈ្មោះ ហាក់ សារិទ្ធិ តាមទំហំផ្ទះស្នាក់នៅ និង កាន់កាប់ខាងក្រោមជាក់ស្តែង ទៀងពន្ធនចាប់ពីសាលក្រមមានប្រសិទ្ធិភាពអនុវត្តន៍ ។

៥- រឹបអូសប្រាក់ប្រដាប់ក្តីរបស់ឈ្មោះ ហាក់ សារិទ្ធិ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ២.០០០៛ រង្វាន់សាក្សី ៣.០០០៛ ។

៦- បង្គាប់អោយឈ្មោះ ហាក់ សារិទ្ធិ បង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ២០០០៛ រង្វាន់សាក្សី ៣.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០៛ ដែលចុងចម្លើយ និង ជាដើមបណ្តឹងតបឈ្មោះ ង៉ោ ហុង បានបង់ទុករួចហើយ ។

កាលបើផុតកំណត់ប្តឹងឧទ្ធរណ៍ បង្គាប់អោយឈ្មោះ ហាក់ សារិទ្ធិ សងប្រាក់ ៧.០០០៛ ទៅអោយឈ្មោះ ង៉ោ ហុង វិញ និង អោយបង់ពន្ធសមាមាត្រ ១ភាគរយ លើតំលៃទែរ៉ាស់

៣.០០០ដុល្លាអាមេរិក "បីពាន់ដុល្លាអាមេរិក" គឺស្មើនឹង ៣០ដុល្លាអាមេរិក "សាមសិបដុល្លាអាមេរិក" ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០ភាគរយ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៧_ សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី និង តតិយជន បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បាន ឃើញបណ្តឹងឧទ្ធរណ៍លេខ ៣១ "ខ" ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់ឈ្មោះ ហាក់ សារិទ្ធិ បានប្តឹងជំទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ ៧៤ "ខ" ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញត្រង់ចំណុចសេចក្តីវិនិច្ឆ័យទាំងមូលនៃសាលក្រម ។

បាន ឃើញសាលដីកា លេខ ១១៧ "ង" ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១_ ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៤.១២.១៩៩៩ របស់ឈ្មោះ ហាក់ សារិទ្ធិ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២_ តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៧៤ "ខ" ចុះថ្ងៃទី ២៣.១២.១៩៩៩ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣_ សំរេចកាត់យកប្រាក់ប្រដាប់ក្តីនៅដាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីការពីបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និង លើអាជ្ញាធរតុលាការ ៥.០០០៛ ។

៤_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បាន ឃើញបណ្តឹងសាទុក្ខលេខ ២៥៩ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០០ របស់លោក ហាក់ សារិទ្ធិ បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ១១៧ "ង" ចុះថ្ងៃទី១២ ខែ មិថុនា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បាន ឃើញសារណាចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០០របស់លោកមេធាវី ចាន់ សុខឃាង "ជាមេធាវីការពារក្តីអោយឈ្មោះ ហាក់ សារិទ្ធិ " ។

បាន ឃើញសារណាតបចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០០ របស់ឈ្មោះ ង៉ោ ហុង ។

បាន ឃើញសារណាតបចុះថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ ២០០០ របស់តតិយជន ឈ្មោះសុខដឹង។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ១១៧ "ង" ចុះថ្ងៃទី ១២.៦.២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់អំណានសារណារបស់ឈ្មោះ ហាក់ សារិទ្ធិ ជាដើមចោទ និងជាម្ចាស់

--- ---

បណ្តឹងសាទុក្ខ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ងៅ ញុង ជាចុងចម្លើយ និង ជាចុងបណ្តឹងសាទុក្ខបាន ឆ្លើយនៅពេលសវនាការថា : ខ្លួនបានទិញផ្ទះនេះតាំងពីឆ្នាំ ១៩៨៥ ហើយឡើងចុះធម្មតា ពុំមានបញ្ហាអ្វីទេ តែនៅពេលឈ្លោះគ្នាគាត់ក៏ហាមខ្លួនមិនអោយឡើង ខ្លួនក៏ដាក់ជណ្តើរដែក ឡើងពីមុខផ្ទះរបស់ខ្លួន រឺ ក៏ឡើងតាមដើមឈើ ។ ហើយជណ្តើរចំនាស់នោះគឺនៅយ៉រផ្ទះរបស់ អ្នកស្រី ឯផ្ទះនេះជាផ្ទះល្វែង ខ្លួននៅ១ល្វែង ហើយបីបន្ទប់ ហើយបន្ទប់នេះមានពីដើមពេលលិច ទឹក ខ្លួនជាអ្នកឡើងទៅជួសជុលដោយខ្លួនសុំគាត់ ការជួសជុលមានចំនួន ៣លើកគឺ ជួសជុលលើក ទី១ នៅឆ្នាំ ១៩៩១ លើកទី២នៅឆ្នាំ១៩៩៦ ខ្លួនចាក់ស៊ីម៉ង់កុំអោយជក់ទឹក នឹងលើកទី៣នៅឆ្នាំ ១៩៩៩ លិចពេកខ្លួនក្រាលកម្រាលថ្មី ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សុខ ជឹង ជាតតិយជន និង ជាចុងបណ្តឹងសាទុក្ខ បានឆ្លើយ នៅពេលសវនាការថា : ខ្លួនទាមទារយកត្រឹមតែរបស់ខ្លួនទេ បន្ទប់ខ្លួនតូចជាងគេ ដំបូល ខាងលើខ្លួនធ្លាប់ជួសជុល ហើយជណ្តើរនេះកាលពីមុនឡើងរួមគ្នា ពេលឈ្លោះគ្នាក៏ដោះស្រាយ រៀងៗខ្លួន ផ្ទះរបស់ខ្លួនផ្ទាល់នឹងដី ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ចាន់ សុខឃាង ការពារអោយដើមចោទ និង ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលសវនាការថា : ក្នុងរឿងនេះដើមចោទបាន អះអាងទាំង៣សាលាសុទ្ធតែខុសពីគ្នា ។ ហើយផ្ទះនេះជាផ្ទះល្វែងមានជណ្តើរឡើងទៅទេរ៉ាស់ ខាងលើ ឯជណ្តើរដែកដែលគាត់ដាក់ពីមុខផ្ទះរបស់គាត់គឺដាក់នៅឆ្នាំ១៩៩៩ ។ ហើយនៅចុងឆ្នាំ ១៩៧៩ និងដើមឆ្នាំ ១៩៨០ គឺជាឆ្នាំដែលកូនក្តីខ្លួនបានរស់នៅរហូតមកដល់បច្ចុប្បន្ន កូនក្តីខ្លួនបាន ប្រើប្រាស់សិទ្ធនៅលើទេរ៉ាស់នេះទៀតផង ឯចុងចម្លើយគ្មានអ្វីសំអាងសោះក្រៅពីចំលើយផ្ទាល់ មាត់នោះ ។ ឯកូនក្តីរបស់ខ្លួនមានសិទ្ធដឹងឮទៀតផង ហើយនៅឆ្នាំ ១៩៨៣-៨៥ មិនដែលមាន ចំនាស់ទេ ទើបតែនៅឆ្នាំ ១៩៩៩ នេះឯងទើបកើតមានចំនាស់ ឯការដែលចុងចម្លើយថា បានធ្វើការជួសជុលនោះគឺ គ្រាន់តែជាលេសប៉ុណ្ណោះ ។ ហើយរាល់ការលើកឡើងគាត់តែងតែ សុំការអនុញ្ញាតិពីកូនក្តីខ្លួននេះជាការបញ្ជាក់អោយឃើញថាជាទេរ៉ាស់របស់កូនក្តីខ្លួន ហើយគាត់ អាងថាគាត់ជាអ្នកកាន់កាប់យ៉ាងម៉េច បើបន្តិចគាត់ឡើងតាមជណ្តើរ បន្តិចឡើងតាមដើមឈើ មើលតែចោរ តើជាម្ចាស់ដែរឬអ្វី ? ឯសាក្សីរបស់គាត់បានឆ្លើយផ្ទុយពីអ្វីដែលគាត់បានអះអាង ហើយសាលដីការបស់សាលាឧទ្ធរណ៍លើកឡើងពុំមានអ្វីពាក់ព័ន្ធដល់អង្គហេតុ និង អង្គសេចក្តីទេ ខ្លួន សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី សែម ចិន្តា ការពារអោយចុងចម្លើយ និង ជាចុងបណ្តឹងសាទុក្ខ នៅពេលសវនាការថា : មេធាវីដែលលើកឡើងថាកូនក្តីរបស់ខ្លួន គ្មានសំអាងនោះខ្លួនសុំលើកឡើងដូចតទៅ : កូនក្តីរបស់ខ្លួនបានទិញផ្ទះនេះពីម្ចាស់ដើមនៅឆ្នាំ ១៩៨៥ គឺទិញពីគ្រួសារ ៥ កាលពីឆ្នាំ ១៩៩៩ មាន ៥គ្រួសារ "កាលពីម្ចាស់ដើម" ហើយជណ្តើរ នោះជាសេរីភាពគាត់ក៏បានឡើងចុះដើម្បីជួសជុលកុំអោយទឹកលិច គឺគាត់បានកាន់កាប់តពីម្ចាស់

--- ---

ដើមរហូតមកដល់សព្វថ្ងៃ ។ ទើបតែនៅឆ្នាំ ១៩៩១ ទើបមានទំនាស់ គេបានហាមមិនអោយកូនក្តីខ្លួនឡើង កូនក្តីខ្លួនក៏ផ្លាះស្រាយដោយខ្លួនឯង ។ ឯការជួសជុលដំបូលផ្ទះនេះកូនក្តីខ្លួនបានសុំ និងមានច្បាប់ទម្លាប់ត្រឹមត្រូវចំនួន ៣លើកមែន ក្នុងនោះសាលដីការបៀបសាលាឧទ្ធរណ៍ក៏បានចុះពិនិត្យដែរ ហើយសាក្សីដែលអ្នកស្រីថា ជាកូនសិស្សរបស់គាត់បានបង្រៀនគួរនៅលើទីទំនាស់ក៏បានឆ្លើយប្រហាក់ប្រហែលគ្នាដែរថា គាត់បានហាលសំលៀកបំពាក់នៅលើទីទំនាស់របស់គាត់មិនមែនហាលទៅលើទីទំនាស់អ្នកផ្សេងទេ និង គំនរឈើដែលគាត់បានគរទុកគឺគាត់គរទុកតែលើទីទំនាស់របស់គាត់ទេ ឯលក្ខណៈបច្ចេកទេសគឺទាក់ទងលើកម្មសិទ្ធិ ហើយការសាងសង់ទំងន់ស្រាលគឺគេមិនបានហាមឃាត់ទេ ។ ដោយគាត់អាងថា គាត់រស់នៅពីឆ្នាំ ១៩៧៩ គាត់បានគ្រប់គ្រងយកទាំងអស់តែម្តង ហើយលោកមេធាវីថា តុលាការថ្នាក់ក្រោមសំរេចយ៉ាងនេះមិនត្រឹមត្រូវនោះមិនពិតទេ ព្រោះការចុះទៅស៊ើបអង្កេតមានលក្ខណៈច្បាស់លាស់ហើយ បើតាមពីអាជ្ញាយុកាលដែលកូនក្តីខ្លួនបានកាន់កាប់គឺរយៈពេលជាង ១០ឆ្នាំហើយ ទើបអ្នកស្រីប្តឹងទាមទារ ដូចនេះបញ្ជាក់ថាអ្នកស្រីមិនបានកាន់កាប់ដំបូលទាំងមូលទេ ដូចនេះអ្នកស្រីថ្លោះសិទ្ធិក្នុងការប្តឹងទាមទារហើយ ខ្លួនសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ចាន់ សុខឃាង ការពារអោយដើមចោទ និង ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលសវនាការថា : ការដែលលោកមេធាវីលើកឡើងក៏មិនត្រឹមត្រូវទេ គាត់បានកាន់កាប់ពីម្ចាស់ដើម ហើយម្ចាស់ដើមបានឆ្លើយថា គាត់កាន់កាប់តែខាងក្រោមទេ មិនបានកាន់កាប់ខាងលើទេ ហើយការដែលគាត់ឆ្លើយថា គាត់សុំជួសជុលពីអាជ្ញាធរមូលដ្ឋាននោះគឺគ្មានទេ ទើបតែមានទំនាស់ហើយទើបសុំ "គ្មានឯកសារណាបញ្ជាក់នោះ" ។ គាត់ថាសំណង់នេះទ្រុឌទ្រោម ហើយថា តុលាការចុះទៅពិនិត្យផ្ទាល់ តែតុលាការមិនមែនជាអ្នកពិនិត្យសំណង់ឯណា ។ ហើយលោកថាកូនក្តីលោកបានកាន់កាប់ជាង ១០ឆ្នាំហើយ តើមានលិខិតណាបញ្ជាក់ ហើយថែមទាំងកូនក្តីលោកមិនបានឆ្លើយថាបានប្រើប្រាស់ពីឆ្នាំ ១៩៧៩ ទៅ ១៩៩១ គ្រប់ជាន់ថ្នាក់ តែអំបាញ់មិញនេះលោកមេធាវី បែរជាអះអាងថាប្រើប្រាស់ពីឆ្នាំ ១៩៧៩ រហូតឆ្នាំ ១៩៩១ ទៅវិញ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់ដើមចោទ ចម្លើយរបស់ចុងចម្លើយ របស់តតិយជន និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ២៥៩ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០០ របស់អ្នកស្រី ហាក់ សារិទ្ធិ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

--- ---

- យល់ឃើញថា : ការលើកឡើងរបស់លោក ចាន់ សុខឃាង មេធាវីការពារអោយអ្នកស្រី ហាក់ សារិទ្ធិក្នុងសារណាចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០០ ថា អ្នកស្រីបានកាន់កាប់ទេរ៉ាស់តាំងពីឆ្នាំ ១៩៧៩ រហូតមកដល់ពេលមានទំនាស់ដោយអាងហេតុថា ជណ្ដើរដែលឡើងទៅកាន់ទេរ៉ាស់ខាងលើស្ថិតក្នុងផ្ទះរបស់អ្នកស្រីនោះគឺ ជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

. ដរាបណាគ្មានសំណង់អ្វីនៅលើទេរ៉ាស់ទេ ទេរ៉ាស់នោះគឺជាដំបូលនៃផ្ទះ ឬ បន្ទប់ខាងក្រោម ដែលជាឧបសម្ព័ន្ធ មិនអាចកាត់ផ្ដាច់បានពីផ្ទះ ឬ បន្ទប់នោះឡើយ។

- យល់ឃើញថា : ដើមចោទបានធ្វើសារណាជូនមកតុលាការកំពូលហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខ ១១៧ "ង" ចុះថ្ងៃទី ១២ ខែ - មិថុនា ឆ្នាំ ២០០០របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខចុងចម្លើយ

តតិយជន មេធាវីការពារអោយគូក្ដី កំបាំងមុខដើមចោទ

ប៉ុន្តែចាត់ទុកជាចំពោះមុខ

១- ទទួលបណ្ដឹងសាទុក្ខលេខ ២៥៩ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០០ របស់អ្នកស្រី ហាក់ សារិទ្ធិ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ១១៧ "ង" ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ១៩.០០០៛ ដែលលោក ងៅ ហុង បានបង់ជូនគឺ:

- ពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛

បង្គាប់អោយអ្នកស្រី ហាក់ សារិទ្ធិ បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការក្រុងភ្នំពេញ ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០១ ។